# តើកម្ពុជាបានផ្សះផ្សាហើយឬនៅ?

បន្ទាប់ពី លន់ នល់ ទម្លាក់សម្តេច សីហនុ នៅខែមីនា ឆ្នាំ ១៩៧០ ប្រជាជនដែលស្មោះស្ម័គ្រដើរតាមការអំពាវនាវរបស់សម្តេច សីហនុ បានចូលបម្រើបដិវត្តន៍ ដោយសង្ឃឹមថាចលនានេះនឹងនាំព្រះអង្គមកកាន់អំណាចវិញ និងដឹកនាំសង្គមជាតិឲ្យបានរុងរឿង។ ប្រជាជនមួយចំនួនទៀតមានជាអាទិ៍ មន្ត្រីរាជការ គ្រូបង្រៀន បណ្ឌិត បញ្ញវន្ត អ្នកមានចំណេះដឹងដែលរស់នៅតាមស្រុកស្រែចម្ការនាំគ្នាផ្លាស់មកនៅទីក្រុងឬទីរួមខេត្តដើម្បីគេចពីសង្គ្រាម និងគេចពីការបង្ខំឲ្យទៅបម្រើបដិវត្តន៍ខ្មែរក្រហម ឬគេចពីការចាប់ខ្លួនដោយខ្មែរក្រហម ។

ប្រជាជនមួយភាគធំឃ្លាតឆ្ងាយពីភូមិកំណើតដែលធ្លាប់រស់នៅបែកបាក់សាច់ញាតិនិងក្រុមគ្រួសារ ។ ប្រជាជនដែលបន្តរស់នៅក្នុងតំបន់រំដោះក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមត្រូវបានបញ្ចុះបញ្ចូលឬចាប់បង្ខំឲ្យស្អប់ខ្ពើមអ្នកដែលបម្រើរដ្ឋាភិបាលលន់នល់ ។ រដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ គឺជាចំណុចចាប់ផ្តើមនៃការបែកបាក់នៅក្នុងសង្គមកម្ពុជានៅសតវត្សរ៍ទី២០ ។

ពេលដែលកងទ័ពខ្មែរក្រហមចូលកាន់កាប់រដ្ឋធានីភ្នំពេញនៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបង្ខិតបង្ខំប្រជាជនឲ្យចាកចេញពីទីក្រុងដោយមិនបានឲ្យដំណឹងជាមុន ។ ប្រជាជនអាចយកត្រឹមតែរបស់របរបន្តិចបន្តួចប៉ុណ្ណោះ ។ មនុស្សចាស់និងអ្នកជំងឺដែលដើរមិនរួច រួមទាំងអ្នកដែលមិនព្រមចេញពីផ្ទះតាមបញ្ជាត្រូវកងទ័ពខ្មែរក្រហមបាញ់សម្លាប់នៅនឹងកន្លែង ។ ប្រជាជនបោះបង់ចោលផ្ទះសម្បែងនិងទ្រព្យសម្បត្តិហើយធ្វើដំណើររាប់រយ

គីឡូម៉ែត្រឆ្ពោះទៅជនបទ ។

ប្រជាជនដទៃទៀតពីទីក្រុង (ដែលខ្មែរក្រហមហៅថា ប្រជាជនថ្មី) ភាគច្រើនធ្វើដំណើរទៅស្រុកកំណើតរបស់ខ្លួន ដោយសង្ឃឹមថានឹងបានជួបសាច់ញាតិនិងមិត្តភក្តិចាស់ៗដែលបែកគ្នាយូរមកហើយ ។ គាត់សង្ឃឹមថាភូមិកំណើតគឺជាកន្លែងដ៏សុខសាន្តសម្រាប់រស់នៅ ប៉ុន្តែការពិតខុសស្រឡះទាំងស្រុងពីអ្វីដែលគាត់គិតទុក ។ បងប្អូនមិត្តភក្តិរបស់គាត់ដែលពេលនោះជាប្រជាជនមូលដ្ឋានចាត់ទុកគាត់ជាចក្រពត្តិ ជាមូលធននាយទុន និយាយឲ្យចំគឺជាសត្រូវ ។ ប្រជាជនថ្មីក្លាយជាមុខសញ្ញាទីមួយដែលខ្មែរក្រហមយកទៅសម្លាប់ ។

បក្សកុម្មុយនិស្តកម្ពុជាបានផ្លាស់ឈ្មោះប្រទេសកម្ពុជាទៅជា "កម្ពុជាប្រជាធិបតេយ្យ" ។ ក្រោមការដឹកនាំរបស់ ប៉ុល ពត បក្សកុម្មុយនិស្តកម្ពុជាបានបង្កើតនូវសង្គមស្មើភាពដោយលុបបំបាត់សាលារៀន សាសនា ក្រដាសប្រាក់ និងទ្រព្យសម្បត្តិឯកជន ។ សមាជិកគ្រួសារនីមួយៗត្រូវបានបង្ខំឲ្យធ្វើការនៅតាមកងជាច្រើនម៉ោងក្នុងមួយថ្ងៃ ហើយទទួលបានរបបអាហារតែបន្តិចបន្តួច ។ រៀងរាល់ពីរឬបីសប្តាហ៍ អង្គការអនុញ្ញាតឲ្យប្រជាជនជនសម្រាកមួយថ្ងៃ ។ អង្គការហាមឃាត់ជាដាច់ខាតមិនឲ្យប្រជាជនជជែកវែកញែកអំពីការលំបាក ស្រេកឃ្លាន ឬនឿយហត់ ។ ប្រសិនបើអ្នកណាម្នាក់លួចនិយាយអំពីបញ្ហានេះ អ្នកនោះនឹងត្រូវអង្គការចាប់យកទៅធ្វើទារុណកម្មឬសម្លាប់ចោល ។

ក្រោយរបបកម្ពុជាប្រជាធិបតេយ្យដួលរលំនៅដើមឆ្នាំ ១៩៧៩ ខ្មែរក្រហមភៀសខ្លួនទៅក្នុងព្រៃនៅតាមព្រំដែនកម្ពុជា-ថៃ និងបន្តគំរាមកំហែងបំភិតបំភ័យប្រជាជន ។ ក្រោមកិច្ចព្រមព្រៀងសន្តិភាព អតីតកងទ័ពខ្មែរក្រហមបានធ្វើសមាហរណកម្ម និងបានវិលត្រឡប់មកស្រុកកំណើតវិញនៅឆ្នាំ១៩៩៦ ។

បើទោះបីជាប្រទេសកម្ពុជាបានបង្រួបបង្រួមខាងវិស័យនយោបាយក៏ដោយ ក៏ប្រជាជនទាំងអស់មិនទាន់បានផ្សះផ្សាខាងផ្លូវចិត្តនៅឡើយទេ ។ អ្វីដែលប្រជាជនកម្ពុជាបានឆ្លងកាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺពិបាកនឹងបំភ្លេច ។ ចំពោះជនរងគ្រោះ ការធ្វើទុកបុកម្នេញឥតត្រាប្រណី ការស្លាប់និងបាត់ខ្លួនរបស់ក្រុមគ្រួសារនិងមិត្តភក្តិមិនមែនជាអ្វីដែលងាយស្រួលនឹងបំភ្លេចទេ ។

អ៊ុយ អ៊ីម អាយុ៧៩ឆ្នាំ បានបាត់បង់កូនពីរនាក់ ។ អ៊ីមមានប្រសាសន៍ថា គាត់ស្អប់ខ្មែរក្រហមសូម្បីតែឈ្មោះក៏មិនចង់ឮផង ។ តាំង គីម ត្រូវកងទ័ពខ្មែរក្រហមរំលោភលើហើយបម្រុងនឹងសម្លាប់គាត់ ប៉ុន្តែគាត់បានរត់រួចពីសេចក្តីស្លាប់ ។ នៅពេលនិយាយដល់ការបង្រួបបង្រួម តាំង គីម និយាយថា "ខ្ញុំឆ្ងល់ថាតើភាគីទាំងពីររួបរួមគ្នាយ៉ាងម៉េចកើត បើម្ខាងជាជនរងគ្រោះហើយម្ខាងទៀតជាជនដៃដល់? ម្យ៉ាងទៀត ជនដៃដល់មិនដែលទទួលកំហុសដែលខ្លួនបានធ្វើផង" ។

ចំណែកជនដៃដល់រស់នៅក្នុងសភាពភ័យខ្លាចថាថ្ងៃណាមួយខ្លួននឹងត្រូវយកទៅកាត់ទោសនៅចំពោះមុខច្បាប់ ។ ជនដៃដល់មិនដែលចាត់ទុកខ្លួនឯងជាឧក្រិដ្ឋជន និងមិនចង់ប្រាប់អំពីមុខងាររបស់ខ្លួនកាលពីរបបកម្ពុជាប្រជាធិបតេយ្យឡើយ ។ ជនដៃដល់មិនចង់ប្រឈមមុខនឹងមនុស្សដែលខ្លួនធ្លាប់ធ្វើបាបទេ ។ សឿន ធ្លាប់ជាសន្តិសុខឃាមគុកខ្មែរក្រហម ។ ពេលគាត់ទៅទស្សនាមន្ទីរ ស-២១ និងឃើញរូបថតអំពីសកម្មភាពដែលខ្មែរក្រហមប្រព្រឹត្តមកលើជនរងគ្រោះ គាត់មិនជឿថានោះជាការពិតឡើយ ។ គាត់បែរជាយល់ថាអ្វីដែលគាត់ឃើញគឺជាទង្វើរបស់មនុស្សមួយក្រុមដែលប្រឆាំងនឹងខ្មែរក្រហម ។ ជនដៃដល់ភាគច្រើនចាត់ទុកខ្លួនឯងថាជាជនរងគ្រោះពីរបបនេះដែរ ។

ជនដៃដល់បន្ទោសមេដឹកនាំរបស់ខ្លួនថាបានបង្ខំខ្លួនឲ្យប្រព្រឹត្តបទល្មើស រីឯមេដឹកនាំបែរជាទម្លាក់កំហុសលើកម្មាភិបាលថ្នាក់ក្រោម ។ ជនរងគ្រោះដាក់ទោសទាំងស្រុងលើជនដៃដល់ថ្នាក់ក្រោមដូចជា ប្រធានភូមិ ឬប្រធានសហករណ៍ ឬឈ្លបជាដើម ។ នរវិទូសញ្ជាតិអាមេរិក អាឡិច ហ៊ិនតុន អះអាងថាការសម្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យធ្វើឡើងដោយកម្មាភិបាលខ្មែរ-ក្រហមថ្នាក់ក្រោម ។ អៀប ឌុច ប្រធានយុវជនស្រុកត្រាំកក់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនិយាយថា ការសម្លាប់មួយចំនួនជាលទ្ធផលនៃជម្លោះនៅក្នុងសហគមន៍ ។

ជនរងគ្រោះដូចជា តាំង គីម និង អ៊ុយ អ៊ីម ទាមទារពេលវេលាច្រើនឆ្នាំដើម្បីអត់អោនទោសឲ្យអ្នកដែលធ្វើបាបគាត់ ។ ហេតុនេះហើយ គ្មានការបង្រួបបង្រួមនៅកម្ពុជាទេដរាបណាប្រជាជនគ្រប់រូបគ្មានការរួបរួមផ្នែកផ្លូវចិត្តរៀងៗខ្លួន ។ ប្រជាជនកម្ពុជាមិនអាចអត់ឱនដល់អ្នកណាម្នាក់ឡើយ លុះត្រាតែបានដឹងថាអ្នកណាមួយដែលខ្លួនត្រូវអត់ទោសឲ្យ ហើយអត់ទោសរឿងអ្វី ។ តាំង គីម និង សឿន មានគំនិតខុសគ្នាស្រឡះ ។ **ញាណ សុជាតិ**